ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

លេខ ៥៧ ប្រក.ណន.សស

ភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

# ប្រកាសណែនាំអនុវត្ត

ដើម្បីអនុវត្តអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមធ្វើការណែនាំអនុវត្តដូចខាងក្រោម ៖

**I- របបសោធននិវត្តន៍**

អ្នករាជការស៊ីវិលទាំងពីរភេទមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១ ២ ៣ នៃអនុក្រឹត្យលេខ ៥៩ អនក្រ បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជកាស៊ីវិល។

**ក- ប្រាក់សោធននិវត្តន៍អតីតភាព**

អ្នករាជការស៊ីវិលទាំងពីរភេទមានសិទ្ធិទទួលរបបសោធននិវត្តន៍អតីតភាពស្មើ ៨០%នៃប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌពីរយ៉ាងដូចខាងក្រោម ៖

១. មានអាយុ ៥៥ឆ្នាំ យ៉ាងតិច និងមានអតីតការងារ ៣០ ឆ្នាំយ៉ាងតិច

២. មានអតីតភាពការងារ ៣០ឆ្នាំឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍មានអាយុ ៥៥ឆ្នាំ ពាក្យស្នើសុំត្រូវធ្វើតាមរយៈអង្គភាពគ្រប់គ្រងផ្ទាល់ទៅប្រធានស្ថាប័នរបស់សាមីខ្លួន។

ប្រាក់សោធននិវត្តន៍អតីតភាពត្រូវអនុវត្តតាមរូបមន្តខាងក្រោម ៖

**សនិសុទ្ធសាធ=៨០% ប**

ប = ប្រាក់បៀវត្សសុទ្ធសាធ

សនិសុទ្ធសាធ = ប្រាក់សោធននិវត្តន៍សុទ្ធសាធ

ប្រាក់សោធននិវត្តន៍នេះ ត្រូវបានគិតបន្ថែមប្រាក់តំបន់ នៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព (ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាពមុនពេលចូលនិវត្តន៍) ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ដែលរដ្ឋបានកំណត់។

**សនិ =៤០%ប + ៣០%ប + ត + ប្រាក់ប៉ះពាល់សុខភាព + ប្រាក់ឧបត្ថម្ភប្រពន្ធ + ប្រាក់ឧបត្ថម្ភកូន + ប្រាក់ឧបត្ថម្ភផ្សេងៗ (បើមាន)**

សនិ = ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ

៣០%ប = ប្រាក់ឧបត្ថម្ភ ៣០% លើប្រាក់បៀវត្សសុទ្ធសាធ

ត = ប្រាក់តំបន់ដែលសាមីជនរស់នៅ (បើមាន)

**ខ- ប្រាក់សោធននិវត្តន៍អប្បបរមា**

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍អប្បបរមាស្មើនឹង ៦០%នៃប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានអាយុ ៥៥ឆ្នាំ យ៉ាងតិច
- មានអតីតភាពការងារ ពី ២០ ឆ្នាំឡើង

ក្នុងករណីមានអតីតភាពការងារលើសពី ២០ ឆ្នាំ អ្នករាជការនោះមានសិទ្ធិទទួលប្រាក់ សមាមាត្របន្ថែម ២%ក្នុងមួយឆ្នាំ លើប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន។ ប្រាក់សោធនសមាមាត្រនេះ មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍អតីតភាព៨០%នៃប្រាក់បៀវត្សសុទ្ធសាធឡើយ បើមានករណីខ្ពស់ជាងត្រូវបន្ថយឱ្យស្មើនឹង៨០% នៃប្រាក់បៀវត្សសុទ្ធសាធវិញ និងមិនត្រូវទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធប្រចាំខែនៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ។ បើមានករណីទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធ ត្រូវដំឡើងឱ្យស្មើនឹងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធនៃតារាងកាំប្រាក់របស់សាមីខ្លួន។

**សនិ =[៦០% + ២% (ឆ២០)]ប + ៣០%ប + ត + ប្រាក់ប៉ះពាល់សុខភាព + ប្រាក់ឧបត្ថម្ភប្រពន្ធ + ប្រាក់ឧបត្ថម្ភកូន + ប្រាក់ឧបត្ថម្ភផ្សេងៗ (បើមាន)**

សនិ = ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ

ប = ប្រាក់បៀវត្សសុទ្ធសាធ

ឆ = ចំនួនឆ្នាំ លើសពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ (២០<ឆ<៣០ )

[ ៦០% +២% (ឆ-២០)]ប = ប្រាក់សោធននិវត្តន៍សុទ្ធសោធ

ប្រាក់បៀវត្សអប្បបរមា ≤ [៦០% +២% (ឆ-២០)] ប ≤ ៨០%ប

៣០%ប = ប្រាក់ឧបត្ថម្ភបន្ថែម ៣០% លើបៀវត្សសុទ្ធសាធ

**គ-** អ្នករាជការដែលត្រូវបានក្រសួង ស្ថាប័នប្រកាសឱ្យចូលនិវត្តន៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សសរុបប្រចាំខែ ចំនួន ៨ខែ ។ ប្រាក់ឧបត្ថម្ភនេះ អាស្រ័យដោយក្រសួង ស្ថាប័ន របស់សាមីជន ជាអ្នកទទួលបន្ទុកដោះស្រាយ ។

**ឃ-** អ្នករាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារតិចជាង ២០ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ។ ក្នុងករណីនេះ រដ្ឋផ្តល់ប្រាក់ឧបត្ថម្ភម្តងគត់ ដូចមានចែកក្នុងមាត្រា ៦ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ។ ការដោះស្រាយប្រាក់ឧបត្ថម្ភមួយលើក អាស្រ័យដោយស្ថាប័នគ្រប់គ្រងរបស់សាមី ។

**បស x ៤ ≤ បឧ ≤ បស x ១០**

បស = ប្រាក់បៀវត្សសរុបប្រចាំខែ

បឧ = ប្រាក់ឧបត្ថម្ភមួយលើក

**ខ-** ការកំណត់ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធកូន ត្រូវអនុវត្តតាមអនុក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២ ស្តីពីការកែលម្អប្រាក់បៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និងសារាចរណែនាំអនុវត្តអនុក្រឹត្យនេះរបស់ក្រសួងពីរដូចខាងក្រោម ៖

១-ក្រសួងផែនការ លេខ ០១ សរណ.ផក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩២

២-ក្រសួងការងារ និង សង្គមកិច្ច លេខ ០៣ សរណន.ចស ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩២

ការបន្ថែមប្រាក់ ១០% លើបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជាការ ត្រូវអនុវត្តតាមលិខិតរបស់ក្រសួងផែនការ លេខ ៣១២ ផក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩២ ។

ការបន្ថែមប្រាក់ ២០% លើបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ត្រូវអនុវត្តតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០៣២ កហវ ចុះថ្ងៃទី ០៤ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ។

**ចៈ-** របៀបគិតរយៈពេលបំពេញការងាររបស់អ្នករាជការ ត្រូវបានអនុវត្តតាមមាត្រា ៨ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

រយៈពេលបម្រើការងារក្រៅក្របខ័ណ្ឌរដ្ឋ មិនត្រូវបានគិតជារយៈពេលបម្រើការងារឡើយ ។

**ឆ-** នៅពេលនិវត្តនជនទទួលមរណៈភាព គ្រួសារនៃសពត្រូវបានរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ។ ការផ្តាច់ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជន ដែលបានទទួលមរណៈភាពខាងលើនេះ ត្រូវបានអនុវត្តនៅខែបន្ទាប់ ។ ឧទាហរណ៍ និវត្តជនមួយនាក់ស្លាប់នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ការផ្តាច់ប្រាក់សោធន ត្រូវបានអនុវត្ត នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។ ក្នុងករណីគ្រួសារសពនិវត្តជន ពុំបានផ្តល់ព័តិមាន និងសំបុត្រមរណៈឱ្យបានទាន់ក្នុងខែដែលបានស្លាប់ អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ត្រូវអនុវត្តការបើកប្រាក់សោធននិវត្តន៍គ្រួសារសពតាមធម្មតា ប៉ុន្តែក្រោយពេលបានទទួលព័តិមាន និងសំបុត្រមរណៈភាពត្រូវផ្តាច់ប្រាក់សោធននៅខែបន្ទាប់នៃការស្លាប់ ។

ប្រាក់សោធនដែលបានបើករួចហើយត្រូវទូទាត់សងរដ្ឋវិញ ។ កូនកំព្រាពីសពនិវត្តជន ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចកូនកំព្រានៃសពអ្នករាជការស៊ីវិលដែរ ។ ការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែនេះ ត្រូវបានអនុវត្តចំពោះកូនកំព្រាដែលមានអាយុរហូតដល់១៥ឆ្នាំ និងចាប់ពីអាយុ ១៥ឆ្នាំ ឡើងទៅត្រូវមានលិខិតបញ្ជាក់ការសិក្សាពីនាយកសាលាដែលកូនកំព្រានោះបាន និងកំពុងសិក្សារៀនសូត្រ ។ លិខិតបញ្ជាក់ការសិក្សារបស់កូនកំព្រាទាំងនោះ ត្រូវផ្ញើមក

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ជារៀងរាល់ចុងខែ វិច្ឆកា នៃឆ្នាំនីមួយៗ។ ក្នុងករណីដល់អាយុបញ្ចប់ការសិក្សា ហើយសាមីគ្រួសារកូនកំព្រានោះ ពុំបានបំពេញតាមការណែនាំរបស់ក្រសួងអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច ការងារ និង អតីតជនយុទ្ធជន ដើម្បីពិនិត្យផ្តាច់ប្រាក់ឧបត្ថម្ភប្រចាំខែនៃកូនកំព្រានោះ ចាប់ពីថ្ងៃទី ០១ ខែ មករា នៃឆ្នាំបន្ទាប់។

ចំពោះសហព័ន្ធ នៃសពជាប្តី ឬប្រពន្ធ ដែលត្រូវបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែបាន លុះត្រា តែប្តី ឬប្រពន្ធនោះបានបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋក្របខ័ណ្ឌរដ្ឋ។ ប្រាក់ឧបត្ថម្ភប្រចាំខែរបស់ប្តី ត្រូវបានអនុវត្តដូចប្រាក់ឧបត្ថម្ភប្រពន្ធដែរ។ ការបើកប្រាក់ឧបត្ថម្ភនេះ ត្រូវបានអនុវត្តជារៀងរហូតដល់ពេលសហព័ន្ធនៃសពត្រូវស្លាប់ ឬមានគ្រួសារថ្មី។ នៅពេលសហព័ន្ធនៃសពត្រូវបានទទួលមរណៈភាព ឬមានប្តី ប្រពន្ធថ្មីទៀត អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីលុបឈ្មោះ និងចុះទិដ្ឋាការលើសៀវភៅបើកប្រាក់ឧបត្ថម្ភ។

II- **របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ**

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១១ និង ១២ នៃ អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជាស៊ីវិល។

**ក- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរិមា** :

អ្នករាជការទាំងពីរភេទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ការងារ ឬ បេសកកម្មត្រូវបានទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ៦៥% នៃប្រាក់បៀវត្សសុទ្ធសាធ។

**១- អំពីគ្រោះថ្នាក់ការងារ**

ត្រូវបានចាត់ទុកជាគ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន ទោះមានហេតុយ៉ាងណាក៏ដោយ ឬ មានកំហុសមកពីអ្នករាជការ ឬគ្មានក៏ដោយ ហើយបណ្តាលឱ្យបាត់បង់សម្បទាវិជ្ជាជីវៈការងារទាំងស្រុង និងជាអចិន្ត្រៃយ៍។

ឧទាហរណ៍: គ្រោះថ្នាក់កើតឡើងក្នុងពេលម៉ោងធ្វើការទាំងក្នុង និងក្រៅក្រសួង ស្ថាប័ន ដែលអ្នករាជការបានបំពេញភារកិច្ចរបស់ខ្លួន។

- គ្រោះថ្នាក់ក្នុងរយៈពេលធ្វើការ និងនៅពេលមុន ឬ ក្រោយពេលធ្វើការ ដែលអ្នករាជការរៀបចំសម្ភារៈពលកម្ម ឬម៉ាស៊ីន។
- គ្រោះថ្នាក់ក្នុងការបំពេញសេចក្តីត្រូវការផ្ទាល់របស់ខ្លួន ក្នុងរយៈពេលធ្វើការ ដូចជា ពេលសម្រាកពេលហូបចុក និងពេលបំបៅកូនកណ្តាលវេន ពេលសំអាតខ្លួននៅពេលក្រោយធ្វើការ។
- គ្រោះថ្នាក់ដែលបណ្តាលមកពីកត្តា ដែលមានគ្រោះថ្នាក់មានពុល ដោយមិនដឹងខ្លួនជាមុន ក្នុងក្រសួង ស្ថាប័ន និងក្នុងផលិតកម្ម ហើយបណ្តាលឱ្យមានរបួសពុលសន្លប់ដល់រាជការ ហើយធ្វើឱ្យបាត់បង់សម្បទាវិជ្ជាជីវៈ ជាស្ថាពរនូវសមត្ថភាពការងារ។
- គ្រោះថ្នាក់ដែលធ្លាក់លើអ្នករាជការ ក្នុងពេលអ្នកទាំងនោះធ្វើដំណើរពីលំនៅដ្ឋានខ្លួនឆ្ពោះត្រង់ទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវៀងទៅទីណាជាប្រយោជន៍ផ្ទាល់ខ្លួន។

**២- អំពីគ្រោះថ្នាក់ការងារនៅពេលបេសកកម្ម**

- គ្រោះថ្នាក់នៅពេលអ្នករាជការញ្ជេញនូវវីរៈភាព ក្នុងការបំពេញបេសកកម្ម ដែលក្រសួង ស្ថាប័ន អង្គភាពប្រគល់ឱ្យ ហើយបានលះបង់ជីវិតរបស់ខ្លួន។
- គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលអ្នករាជការការពារទ្រព្យសម្បត្តិរដ្ឋ ឬសាធារណៈ ដូចជាភ្លើងឆេះផ្ទះ ទឹកជំនន់។ល។
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរិមា ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

**សពិសុទ្ធសោធ =៦៥% ប**

សពិសុទ្ធសាធ = ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសោធ

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈនេះ ត្រូវបានគិតបន្ថែមប្រាក់តំបន់នៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព (ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ដូចពេលកំពុងបម្រើការងារមុនពេលចូលបាត់បង់សម្បទាវិជ្ជាជីវៈ) ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំណត់ ៖

**សពិ=៦៥%ប+៣០%ប+ត+ប្រាក់ប៉ះពាល់សុខភាព+ប្រាក់ឧបត្ថម្ភប្រពន្ធ+ប្រាក់ឧបត្ថម្ភកូន**

**+ប្រាក់ឧបត្ថម្ភផ្សេងៗទៀត (បើមាន)**

សពិ = ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែ

៣០%ប = ប្រាក់ឧបត្ថម្ភ ៣០% លើប្រាក់ឧបត្ថម្ភសុទ្ធសាធ

**ខ- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា**

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា ត្រូវកំណត់ ៥០% នៃប្រាក់បៀវត្សសុទ្ធសាធ។ ប្រាក់សោធននេះត្រូវ អនុវត្តតែចំពោះអ្នករាជការណាដែលបាត់បង់សម្បទាវិជ្ជាជីវៈដោយសារជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗ។ ចំពោះអ្នករាជការ ដែលមានអតីតភាពការងារលើសពី ២០ឆ្នាំឡើងទៅ ត្រូវទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា និងត្រូវទទួលប្រាក់សមាមាត្របន្ថែម ១.៥% ក្នុងមួយឆ្នាំ លើប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន។ ប៉ុន្តែប្រាក់សោធនសមាមាត្រនេះ មិនត្រូវលើសប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរិមា ឬមិនត្រូវទាបជាង ៩០% នៃប្រាក់បៀវត្សអប្បបរមាសុទ្ធសាធនៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ។

**សពិសុទ្ធសោធ= [៥០% + ១.៥% (ឆ-២០)] ប**

ឆ = ចំនួនឆ្នាំដែលបានបម្រើការងាររដ្ឋលើសពី ២០ឆ្នាំឡើង

២០ឆ្នាំ < ឆ < ៣០ឆ្នាំ

៩០%ប≤ [ ៥០% +១.៥%(ឆ-២០)]ប ≤៦៥%ប

| |
|---|
| សពិ=[៥០% +១.៥% (ឆ-២០)] ប+ ៣០%ប+ ត+ ប្រាក់ប៉ះពាល់សុខភាព+ ប្រាក់ឧបត្ថម្ភប្រពន្ធ+ ប្រាក់ឧបត្ថម្ភកូន+ ប្រាក់ឧបត្ថម្ភផ្សេងៗ (បើមាន) |

**គ-** ការកំណត់ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន ត្រូវបានអនុវត្តដូចនិវត្តជនដែរ

**ឃ-** អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានអនុវត្តរបៀបគិតរយៈពេលបំពេញការងារ ដូចនិវត្តជនដែរ។ ដោយឡែក ក្រោយពេលតម្រូវឱ្យចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវទទួលប្រាក់ខែឧបត្ថម្ភម្តងគត់ស្មើនឹងប្រាក់បៀវត្សរសរុប ប្រចាំខែចំនួន ៧ខែ ។ ប្រាក់ឧបត្ថម្ភនេះអាស្រ័យ ស្ថាប័ន របស់សាមីជន ជាអ្នកទទួលបន្ទុកដោះស្រាយ ។

**ង-** អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណៈភាព គ្រួសារនៃសពត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧។

ចំពោះរបៀបរបបអនុវត្តការផ្តាច់ប្រាក់សោធន និងការផ្តល់ប្រាក់ឧបត្ថម្ភគ្រួសារក្នុងបន្ទុកត្រូវអនុវត្តដូចនិវត្តជនទទួលមរណៈភាពដែរ។

## III- ការបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ កូនសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលបានប្រាក់សោធនប្រចាំខែកន្លងមក

ការគិតបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ កូន ជូននិវត្តជន និងជនបាត់បងសម្បទាវិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ១៧ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ត្រូវបានអនុវត្តចាប់ពីថ្ងៃ ០១ ខែ មីនា ឆ្នាំ ១៩៩៨ តទៅ។

និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនកន្លងមក ត្រូវគិតបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធដែលពុំបានបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋ និងប្រាក់ឧបត្ថម្ភកូន ក្នុងបន្ទុកដែលមានអាយុរហូតដល់ ១៥ ឆ្នាំ និងចាប់ពីអាយុ ១៥ឆ្នាំ ឡើងត្រូវមានលិខិតបញ្ជាក់ការសិក្សាពីនាយកសាលាដែលកូននោះកំពុងសិក្សារៀនសូត្រ។ ប្រពន្ធ និង កូន ដែលត្រូវផ្តាច់ប្រាក់ឧបត្ថម្ភប្រចាំខែ លុះត្រាតែមានករណីដូចខាងក្រោម ៖

– ប្រពន្ធស្លាប់

– កូនលើសអាយុ ១៥ ឆ្នាំ គ្មានលិខិតបញ្ជាក់ការសិក្សា ឬមានអាហារូបត្ថម្ភ។

## IV- ភារកិច្ច និងសមត្ថកិច្ចនៃការគ្រប់គ្រងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

### ក- ភារកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗមានដូចខាងក្រោម ÷

– ត្រូវលើកគម្រោងផែនការស្ថិតិ និងថវិកាប្រចាំឆ្នាំ សម្រាប់អ្នករាជការក្រោមឱវាទដែលគ្រប់លក្ខខណ្ឌចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ជូនក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនដំណាច់ខែសីហានៃឆ្នាំ ដើម្បីបម្រុងថវិកាសម្រាប់បើកផ្តល់ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។ ចំពោះក្រសួង ស្ថាប័ន ដែលគ្មានគម្រោងផែនការស្ថិតិ និងថវិកាផ្ញើមកតាមការកំណត់នោះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ពុំអាចចេញសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជូនបានឡើយ។

– លើកគម្រោងផែនការ ថវិកា និងបើកប្រាក់ឧបត្ថម្ភលើកដំបូងជូនអ្នករាជការ ដែលបានប្រកាសឱ្យចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ។ ប្រាក់ឧបត្ថម្ភលើកដំបូងនេះត្រូវស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

– ត្រូវធ្វើសំណើសុំចេញសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ឱ្យបានបីខែមុនពេលប្រកាសឱ្យអ្នករាជការក្រោមឱវាទចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ។ ករណីយឺតយ៉ាវ មិនទាន់តាមពេលកំណត់នេះ ក្រសួងមិនទទួលដោះស្រាយជូនឡើយ។ បណ្តាសំណុំលិខិតដែលត្រូវបញ្ជូនមកក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនមានដូចតទៅ៖

- ពាក្យស្នើសុំចេញសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ច្បាប់
- ប្រកាសឱ្យចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ(ច្បាប់ដើម១) ចំនួន ០២ច្បាប់
- លិខិតបញ្ជាក់អំពីរយៈពេលបំពេញការងាររបស់អ្នករាជការ ចំនួន ០២ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីជន ចំនួន ០២ច្បាប់
- ពាក្យសុំចូលនិវត្តន៍របស់អ្នករាជការដែលមានអតីតភាពការងារ ៣០ ឆ្នាំឡើង មិនទាន់គ្រប់អាយុ ហើយស្ម័គ្រចិត្តសុំចូលនិវត្តន៍ ចំនួន ០១ច្បាប់
- សេចក្តីសម្រេចឱ្យបន្តការងារមួយឆ្នាំម្តងៗ បើអ្នករាជការនោះមានអាយុលើសពី ៥៥ ឆ្នាំឡើងទៅ ចំនួន ០១ច្បាប់
- លិខិតបញ្ជាក់ការងារប៉ះពាល់សុខភាព បើអ្នករាជការនោះធ្វើការនៅកន្លែងប៉ះពាល់សុខភាព ចំនួន ០១ច្បាប់
- វិញ្ញាបនប័ត្របញ្ជាក់បាត់បង់សម្បទាវិជ្ជាជីវៈ ចេញដោយគណៈកម្មការវាយតម្លៃសុខភាព បើអ្នករាជការនោះបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ច្បាប់
- កំណត់ហេតុស្តីពីគ្រោះថ្នាក់ការងារ ឬ បេសកកម្ម បើអ្នករាជការនោះទទួលគ្រោះថ្នាក់ដោយបំពេញការងារ ឬ បេសកកម្ម ចំនួន ០១ច្បាប់
- រូបថតទំហំ ៤ គុណ ៦ ចំនួន ០៣សន្លឹក
- រូបថតទំហំ ៣ គុណ ៤ ចំនួន ០១សន្លឹក

ទម្រង់បែបបទសំខាន់ៗខាងលើ ដូចមានជូនភ្ជាប់មកជាមួយនេះនូវគំរូតារាងឧបសម្ព័ន្ធ។

**ខ- ភារកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

**១- ថ្នាក់កណ្តាល**

– ពិនិត្យសំណើសុំចេញសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈនៃអ្នករាជការរបស់ក្រសួងស្ថាប័នរដ្ឋ។

– ចេញសៀវភៅបើកប្រាក់សោធនប្រចាំខែ និងអត្តសញ្ញាណប័ណ្ណ ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

- ពិនិត្យ និងចេញប្រកាសលុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលមុខសញ្ញាទទួលមរណៈភាព និង ចេញសៀវភៅបើកប្រាក់ឧបត្ថម្ភជូនគ្រួសារសព តាមសំណើរបស់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជនខេត្ត ក្រុង។
- ពិនិត្យ និង ចេញសៀវភៅសោធនទុតិយតារបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលសៀវភៅបើកប្រាក់សោធនប្រចាំខែត្រូវបាត់បង់ ឬប្រើប្រាស់អស់។
- ពិនិត្យ និងផ្ទេរការផ្លាស់ប្តូរទីលំនៅរបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ តាមសំណើរបស់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជនខេត្ត ក្រុង។
- គ្រប់គ្រង តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយសោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៅគ្រប់លំដាប់ថ្នាក់ក្រោមឱវាទរបស់ក្រសួង។

**២- ថ្នាក់អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង**

- គ្រប់គ្រង និងបើកប្រាក់សោធនប្រចាំខែជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលរស់នៅតាមខេត្ត ក្រុងរបស់ខ្លួន។
- ជារៀងរាល់ឆ្នាំ អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ត្រូវធ្វើគម្រោងផែនការស្ថិតិ និងថវិកា និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងគ្រួសារក្នុងបន្ទុកដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខេត្ត ក្រុងនោះ ដើម្បីផ្ញើមកក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ឱ្យបានមុនដំណាច់ខែសីហានៃឆ្នាំ។
- ធ្វើសំណើទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បី ៖

២.១- លុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលមុខសញ្ញានោះបានទទួលមរណៈ-ភាព ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យសុំប្រាក់ឧបត្ថម្ភគ្រួសារ ចំនួន ០១ច្បាប់
- សំបុត្របញ្ជាក់មរណៈភាពរបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ច្បាប់
- វិញ្ញាបនប័ត្រផ្តាច់ទឹកប្រាក់សោធននិវត្តន៍
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ចំនួន ០១ច្បាប់

២.២- សុំផ្ទេរការស្នាក់នៅរបស់និវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលសាមីជនមានសំណើមកអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។ សំណុំលិខិតត្រូវភ្ជាប់មកក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន មាន ៖

- ពាក្យស្នើសុំផ្ទេរការស្នាក់នៅរបស់អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ចំនួន ០១ច្បាប់
- តារាងទូទាត់ប្រាក់សោធនប្រចាំខែចុងក្រោយរបស់សាមីជន ចំនួន ០១ច្បាប់
- ពាក្យស្នើសុំផ្ទេររបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ច្បាប់

- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ

២.៣- សុំចេញសៀវភៅសោធនទុតិយតា ចំពោះករណី និវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបាត់បង់សៀវភៅសោធនចាស់ ។ សំណុំលិខិតភ្ជាប់មកជាមួយមាន ៖

- ពាក្យសុំចេញសៀវភៅទុតិយតារបស់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ខេត្ត ក្រុង ចំនួន ០១ច្បាប់
- កំណត់ហេតុស្ដីពីការបាត់បង់សៀវភៅ ចំនួន ០១ច្បាប់
- តារាងប្រាក់សោធនប្រចាំខែ ចំនួន ០១ច្បាប់

២.៤- សុំចេញសៀវភៅថ្មីជូននិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ក្នុងករណីសៀវភៅចាស់ត្រូវបានប្រើប្រាស់អស់ ។ សំណុំលិខិតផ្ញើមកក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជនមាន ៖

- ពាក្យសុំចេញសៀវភៅថ្មី ដោយអធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ខេត្ត ក្រុង ចំនួន ០១ច្បាប់
- សៀវភៅនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈដែលបានប្រើប្រាស់អស់

២.៥- សុំបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ កូន របស់និវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកន្លងមកពុំបានទទួលប្រាក់ឧបត្ថម្ភ ។ សំណុំលិខិតភ្ជាប់មកជាមួយនេះរួមមាន ៖

- លិខិតស្នើសុំប្រាក់ឧបត្ថម្ភរបស់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ខេត្ត ក្រុង ចំនួន ០១ច្បាប់
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- តារាងរៀបរាប់ស្ថានភាពគ្រួសារ ដែលត្រូវបានទទួលប្រាក់ប្រចាំខែ ចំនួន ០១ច្បាប់

(តារាងនេះត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក)

២.៦- សុំចេញអត្តសញ្ញាណប័ណ្ណជូននិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកំពុងរស់នៅតាមខេត្ត ក្រុងរបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាមនិង រូបថតទំហំ ៣ គុណ ៤ ចំនួន ០១សន្លឹក

- ជារៀងរាល់ត្រីមាសនៃឆ្នាំ អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង ត្រូវផ្ដល់បញ្ជីបើកប្រាក់សោធននិវត្តន៍ និងសោធនជនបាត់បង់សម្បទាវិជ្ជាជីវៈ និងតារាងបើកប្រាក់ឧបត្ថម្ភគ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។
- រាល់ការបើកប្រាក់សោធន និងប្រាក់ឧបត្ថម្ភគ្រួសារប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវមានវត្តមានរបស់មន្ត្រីតំណាងការិយាល័យសង្គមកិច្ច ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។

- អនុវត្តកម្មវិធីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពជីវភាពរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងគ្រួសារក្នុងបន្ទុកឱ្យបានជាប់ជាប្រចាំក្នុងមួយឆ្នាំយ៉ាងតិច២ដង។ លទ្ធផលការងារនេះ ត្រូវមានរបាយការណ៍បញ្ជូនទៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។
- កំណត់ណែនាំភារកិច្ច ជាក់ស្តែងសម្រាប់ការិយាល័យក្រោមឱវាទរបស់អធិការដ្ឋានផ្ទាល់ ។

ទម្រង់បែបបទសំខាន់ៗខាងលើ ដូចមានគំរូជូនភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ។

ប្រកាសណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

**<u>ចម្លងជូន</u>:**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទាំងពីរ
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់អង្គភាពក្រោមឱវាទ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន
- គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ខេត្ត ក្រុង
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ